មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០១៨

ឈ្មោះស្ថាប័ន	**មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”)**
គោលដៅគម្រោង	ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឲ្យកម្ពុជាក្លាយទៅជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សា ដែលប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន មានសមភាពនិងត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួលបានប្រយោជន៍ពីការអភិវឌ្ឍប្រទេស។ ម.ស.ម.ក គឺជាអង្គការឯករាជ្យ មិនចូលបក្សសម្ពន្ធ ដែលធ្វើការងារផ្តែកទៅលើតម្លៃសមភាព អព្យាក្រឹត្យភាព តម្លាភាព និងការមិនរើសអើង។
រយៈពេល	ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០១៨

ក្នុងអំឡុងពេលពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៨ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) អនុវត្តសកម្មភាពការងាររបស់ខ្លួន ដូចមានរៀបរាប់ខាងក្រោម ៖

១. ទស្សនភាពនៃសកម្មភាព

ក្នុងអំឡុងរយៈពេលនៃរបាយការណ៍នេះ ម.ស.ម.ក បានចេញឯកសារផ្សព្វផ្សាយចំនួន ៧១ ពាក់ព័ន្ធនឹងសិទ្ធិមនុស្សក្នុងនោះរួមមាន សេចក្តីថ្លែងការណ៍ លិខិតចំហ សេចក្តីថ្លែងការណ៍រួម សេចក្តីប្រកាសព័ត៌មាន បន្ទាន់អំពីអ្នកការពារសិទ្ធិមនុស្ស កំណត់ត្រាសង្ខេប របាយការណ៍ស្រាវជ្រាវ សលាកបត្រព័ត៌មាន របាយការណ៍រួមផ្តោតលើបញ្ហាជាក់លាក់ ប័ណ្ណព័ត៌មាន និងខិតប័ណ្ណព័ត៌មានមួយចំនួនទៀត។ ឯកសារទាំងនេះចេញផ្សាយក្នុងគោលបំណងតស៊ូមតិ អប់រំ និងលើកកម្ពស់ការយល់ដឹងអំពីបញ្ហាសិទ្ធិមនុស្សជាច្រើនផ្សេងៗ រួមមានសេរីភាពមូលដ្ឋាន សិទ្ធិដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្ស និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ សិទ្ធិជនជាតិដើមភាគតិច និងការចូលរួមក្នុងនយោបាយ។

ជាលទ្ធផលនៃការបន្តឃ្លាំមើលសារព័ត៌មាននៅឆ្នាំ២០១៨ ម.ស.ម.ក ឃ្លាំមើលសារព័ត៌មានក្នុងគោលបំណងទទួលបានព័ត៌មានទាន់ហេតុការណ៍ជុំវិញព្រឹត្តិការណ៍នានា និងបញ្ហាសំខាន់ៗមួយចំនួនដែលផ្តោតទៅលើសិទ្ធិដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្សជាទូទៅ សិទ្ធិស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ («អ្នកស្រឡាញ់ភេទដូចគ្នា») និងស្ថានភាពនៃសេរីភាពមូលដ្ឋាននៅទូទាំងប្រទេស។ ជាសរុប

ក្នុងរយៈពេលនៃរបាយការណ៍នេះ ម.ស.ម.ក បានប្រមូលព័ត៌មានសរុបចំនួន៥១០៤ អត្ថបទដែលចេញផ្សាយ ពាក់ព័ន្ធនឹងសេរីភាពខាងការជួបប្រជុំ និងសេរីភាពជាមូលដ្ឋានផ្សេងទៀត ដូចជាសិទ្ធិដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្ស សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា និងសិទ្ធិស្ត្រីជាដើម។

នៅក្នុងឱកាសនៃទិវាសិទ្ធិនារីអន្តរជាតិថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ ម.ស.ម.ក បានចេញផ្សាយសេចក្តីថ្លែងការណ៍រួមមួយមានចំណងជើងថា «អង្គការសង្គមស៊ីវិលរៀបចំកម្មវិធីផ្សព្វផ្សាយគម្រោងសមភាពយេនឌ័រ និងសូមអំពាវនាវឱ្យរដ្ឋាភិបាលបង្កើនការគាំទ្រដល់ស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នា» និងប័ណ្ណព័ត៌មានអំពីសិទ្ធិស្ត្រី ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិស្ត្រីតាមក្របខ័ណ្ឌច្បាប់ជាតិនិងច្បាប់អន្តរជាតិ។ ម្យ៉ាងទៀត គម្រោងសង្កេតការណ៍សវនាការបានចេញផ្សាយព្រឹត្តិបត្រព័ត៌មានចំនួនពីរ(មួយពាក់ព័ន្ធនឹង«សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សម្រាប់ស្ត្រីនៅកម្ពុជា»និងមួយទៀតស្តីពី«សិទ្ធិទទួលបានសេចក្តីសម្រេចដែលមានសំអាងហេតុ» ព្រមទាំងរបាយការណ៍ប្រចាំឆ្នាំមួយស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា៖ ការសង្កេតការណ៍នៅសាលាឧទ្ធរណ៍ ដែលបានគ្របដណ្តប់ចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៦ ដល់ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០១៧។

លើសពីនេះ ក្នុងអំឡុងរយៈពេលនៃរបាយការណ៍នេះ ម.ស.ម.ក បានរៀបចំការផ្សាយផ្ទាល់កម្មវិធីពិភាក្សាវិទ្យុចំនួន១៤២ លើកដោយផ្តោតលើប្រធានបទនានាតាមវិស័យនីមួយៗដូចមានបញ្ជាក់ក្នុងកថាខ័ណ្ឌខាងលើមានដូចជា ដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្ស សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ការពិភាក្សាអំពីច្បាប់ និងការវិភាគប្រចាំសប្តាហ៍។ ក្នុងកម្មវិធីពិភាក្សាទាំងនោះសុទ្ធតែមានការអញ្ជើញភាគីពាក់ព័ន្ធសំខាន់ៗពីសង្គមស៊ីវិល និងអាជ្ញាធររដ្ឋាភិបាលដើម្បីចូលរួមចែករំលែកនូវគំនិតយោបល់របស់ពួកគេ។ រាល់កម្មវិធីពិភាក្សាទាំងអស់ក៏មានផ្សព្វផ្សាយបន្តផ្ទាល់នៅលើទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក ផងដែរ ដែលទទួលបានការចុច Like ចំនួន ៥៤៤៧ ចែករំលែកបន្តចំនួន២២៥៥ និងចូលទស្សនាចំនួន ១៣៣៦៦២ ។

ម.ស.ម.ក បានរៀបចំវគ្គបណ្តុះបណ្តាល វគ្គបណ្តុះបណ្តាលគ្រូបង្គោល កិច្ចប្រជុំឆ្លុះបញ្ចាំង កម្មវិធីសិក្ខាសាលា កិច្ចពិភាក្សាតុមូល កិច្ចសន្ទនា ការប្រជុំធ្វើបច្ចុប្បន្នភាពទាក់ទងនឹងការតស៊ូមតិ ច្បាប់ ធុរកិច្ចនិងសិទ្ធិមនុស្ស និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ចំនួន១៦ លើក ដោយមានអ្នកចូលរួមសរុបចំនួន ៣២៦ នាក់ (ក្នុងនោះស្ត្រីមានចំនួន៩៩ នាក់)។ លើសពីនេះក៏មានកិច្ចប្រជុំចំនួន១២ លើកផ្សេងទៀតផងដែរ រួមមានការប្រជុំបណ្តាញ កិច្ចពិភាក្សាជាមួយក្រុមគោលដៅ និងកម្មវិធីផ្សព្វផ្សាយមួយចំនួនផងដែរដោយមានអ្នកចូលរួមចំនួន ១៩២ (ក្នុងនោះស្ត្រីមានចំនួន៩៩នាក់)។ ឧទាហរណ៍មួយក្នុងចំណោមវគ្គបណ្តុះបណ្តាលនោះគឺកម្មវិធីវគ្គបំពាក់បំប៉ននិតីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែល ម.ស.ម.ក បានរៀបចំឡើងរយៈពេលបីថ្ងៃដោយមានការចូលរួមពីនិស្សិតច្បាប់។ នៅថ្ងៃចុងក្រោយនៃកម្មវិធីនេះ ម.ស.ម.ក បានសម្របសម្រួលអោយនិស្សិតទាំងនោះបានចូលរួមសង្កេតការណ៍សវនាការដើម្បីឈ្វេងយល់បន្ថែមអំពីនីតិវិធីនៃការជំនុំជម្រះ។ ក្រោយមកទៀតមានការរៀបចំកម្មវិធីសិក្ខាសាលាឆ្លុះបញ្ចាំងរយៈពេលមួយថ្ងៃ ដោយពេលព្រឹកធ្វើការសង្កេត

ការណ៍សវនាការ ហើយពេលរសៀលពិភាក្សាអំពីលទ្ធផលដែលទទួលបានពីវគ្គបណ្តុះបណ្តាល។ វគ្គបណ្តុះបណ្តាលនោះមានការចូលរួមពីនិស្សិតចំនួន ៣០ នាក់ (ក្នុងនោះមានស្ត្រីចំនួន ៨ នាក់ និងអ្នកស្រឡាញ់ភេទដូចគ្នា ២នាក់)។ យោងតាមការវាយតម្លៃដែលអ្នកចូលរួមបានបំពេញ ភាគច្រើននៃអ្នកចូលរួមបានពេញចិត្តនឹងកម្មវិធីនោះនិងចង់ឱ្យមានកម្មវិធីនេះបន្ថែមទៀត។ អ្នកចូលរួមបានលើកឡើងអំពីសារៈសំខាន់ក្នុងកម្មវិធីថាពួកគេអាចឆ្លើយសំណួរនានាក្នុងកម្មវិធីប្រឡងប្រជែងជ្រើសរើសសិស្សក្រឡាបញ្ជីផងដែរ។

ឧទាហរណ៍មួយផ្សេងទៀតគឺសិក្ខាសាលាពិគ្រោះយោបល់។ នៅក្នុងឱកាសនៃទិវាមោទកភាពនិងទិវាអន្តរជាតិប្រឆាំងនឹងការស្អប់ខ្ពើមអ្នកស្រឡាញ់ភេទដូចគ្នា ការប្រព្រឹត្តមិនត្រឹមត្រូវចំពោះអ្នកប្តូរភេទនិងការស្អប់ខ្ពើមអ្នកស្រឡាញ់ទាំងពីរភេទនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ម.ស.ម.ក បានសហការរៀបចំកិច្ចពិភាក្សាអំពីគោលនយោបាយសាធារណៈដើម្បីលើកកម្ពស់សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា។ អង្គការសង្គមស៊ីវិលដែលធ្វើការងារផ្នែកលើកកម្ពស់និន្នាការភេទ និងអត្តសញ្ញាណយេនឌ័របានចូលរួមក្នុងកម្មវិធីនេះ ព្រមទាំងតំណាងមកពីក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ កម្មវិធីនេះមានគោលបំណងលើកម្ពស់កិច្ចសន្ទនា និងកិច្ចពិភាក្សាដើម្បីស្វែងរកបញ្ហាជាអាទិភាពរបស់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា និងស្វែងរកជំនួយផ្លូវច្បាប់ និងគោលនយោបាយតាមវិស័យពាក់ព័ន្ធដើម្បីដោះស្រាយនូវបញ្ហាអាទិភាពជាក់លាក់មួយចំនួន ដូចជា ៖ (ក) បញ្ហាពាក់ព័ន្ធនឹងច្បាប់ ក្នុងនោះរាប់ទាំង អាពាហ៍ពិពាហ៍ភេទដូចគ្នា ការស្នុំកូន និងលទ្ធភាពនៃការផ្លាស់ប្តូរយេនឌ័រផ្នែកតាមស្វ័យសម្រេចរបស់បុគ្គលម្នាក់ៗនៅលើឯកសារផ្លូវច្បាប់នានា (អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ និងលិខិតឆ្លងដែន) (ខ) ការរើសអើង និងការដាក់ចេញពីសំណាក់គ្រួសារ និងសាលារៀន (គ) ឱកាសការងារ និងការរើសអើងនៅកន្លែងការងារ។

ជាផ្នែកនៃគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ក្នុងឆ្នាំ២០១៨ ម.ស.ម.ក បានសង្កេតការណ៍សវនាការក្នុងករណីព្រហ្មទណ្ឌចំនួន២៣៤ នៅសាលាឧទ្ធរណ៍។

ម.ស.ម.ក ក៏បានផលិតវីដេអូអប់រំចំនួនពីរ។ វីដេអូទីមួយមានចំណងជើងថា គាំទ្រអ្នកការពារបរិស្ថានក្នុងគោលបំណងដើម្បីបង្ហាញអំពីសារៈសំខាន់ការងារនៃអ្នកការពារសិទ្ធិមនុស្សផ្នែកបរិស្ថានដែលជើរតួនាទីក្នុងការការពារបរិស្ថាននិងធនធានធម្មជាតិ។ វីដេអូនេះត្រូវបានផ្សព្វផ្សាយនៅលើយូធូប និងទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក ។ វីដេអូនេះទទួលបានការចាប់អារម្មណ៍ជាខ្លាំងនៅលើទំព័រហ្វេសប៊ុក ដោយមានការចែករំលែកបន្តចំនួន១៨៣ ចុច likes ចំនួន១២២ និងចូលទស្សនាចំនួន៣៩,០០០[1] គិតត្រឹមថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៨។ វីដេអូទីពីរស្តីពីវគ្គបំពាក់បំប៉នស្តីពី សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងការសង្កេតការណ៍សវនាការដែលបង្ហាញពីបទពិសោធន៍ និងទស្សនៈរបស់និស្សិតដែលចូលរួមកម្មវិធីបំពាក់បំប៉ននោះ។ វីដេអូនេះត្រូវបានផ្សព្វផ្សាយនៅលើយូធូប និងទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក។ វីដេអូនេះ ត្រូវបានចែករំលែកបន្តចំនួន៣៤ ចុច Likes ចំនួន ១៤៧ និងចូលទស្សនាចំនួន ៨២,០០០ គិតត្រឹមថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨។

[1] ការចូលទស្សនា៖ ចំនួនដងដែលចូលទស្សនាការបង្ហោះយ៉ាងតិច ៣ វិនាទី ប្រភព៖ http://bit.ly/1upJLvd.

ក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ ម.ស.ម.ក ក៏បានផលិតល្ខោននិយាយវិទ្យុចំនួន៤ផងដែរ ៖ ល្ខោននិយាយទី១ មានចំណងជើង អ្នកបន្តវេន ទី២ ពាក្យពិត ទី៣ ដើម្បីអ្នក និងទី៤ អ្នកតាព្រៃ។ ម.ស.ម.ក ក៏បានផលិតខិត្តប័ណ្ណព័ត៌មានមួយស្តីពីការត្រួតពិនិត្យជាសកលតាមកាលកំណត់ និងប្រទេសកម្ពុជា បច្ចុប្បន្នភាពត្រឹមខែសីហា ឆ្នាំ២០១៧ ផងដែរ។

២. សកម្មភាពដែលជំរុញការបានល្អ និងមិនល្អ

ម.ស.ម.ក បានភ្ជាប់ទំនាក់ទំនងជាមួយអាជ្ញាធរនិងវិស័យឯកជនតាមរយៈការផ្តល់វគ្គសិក្ខាសាលាស្តីពី «ការផ្តល់សំណង និងការទទួលខុសត្រូវរបស់រដ្ឋ» ដែលពាក់ព័ន្ធទៅនឹងបញ្ហាសិទ្ធិមនុស្សជាមួយនឹងសកម្មភាពរបស់តួអង្គឯកជន និង «កាតព្វកិច្ចរបស់រដ្ឋ និងការយកចិត្តទុកដាក់ចំពោះសិទ្ធិមនុស្ស» ដោយផ្អែកតាមគោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។ យ៉ាងតិចណាស់មានអ្នកចូលរួមចំនួន២៦ នាក់ (ក្នុងនោះមានស្ត្រីចំនួន ៣នាក់) ដែលជាអាជ្ញាធរមកពីថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិបានចូលរួមសិក្ខាសាលាចំនួន៣ របស់ ម.ស.ម.ក។

អង្គការមិនមែនរដ្ឋាភិបាលនៅតែត្រូវបានតម្រូវអោយបំពេញនូវលក្ខខណ្ឌរដ្ឋបាលមួយចំនួន ក្នុងនោះរួមទាំងការតម្រូវអោយរាយការណ៍ទៅអាជ្ញាធរ។ នៅខែតុលា ឆ្នាំ២០១៨ តាមរយៈសេចក្តីជូនដំណឹងរបស់ស្នងការនគរបាលរាជធានីភ្នំពេញបានដាក់ចេញនូវយុទ្ធសាស្ត្រមួយដើម្បីគ្រប់គ្រងសកម្មភាពរបស់បុគ្គលទាំងឡាយណាដែលរិះគន់លើរដ្ឋាភិបាល ក្នុងនោះរួមទាំងការឃ្លាំមើលសកម្មភាពរបស់អង្គការសង្គមស៊ីវិលផងដែរ។ នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ក្រសួងមហាផ្ទៃបានកែសម្រួលនូវលក្ខខណ្ឌតម្រូវអោយអង្គការជូនដំណឹងអោយបាន ៣ ថ្ងៃមុន (មានលើកឡើងតាមរយៈសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៧) និងបានណែនាំអោយអាជ្ញាធររាជធានី ខេត្ត សម្រួលដល់សកម្មភាពរបស់អង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន «ដោយពុំមានការរឹតត្បិត» តែយ៉ាងណាក្តីនៅពុំទាន់ច្បាស់លាស់ថាតើនេះអាចឈានដល់ការអនុវត្តសេចក្តីណែនាំនោះដោយពេញលេញឬយ៉ាងណា។

ម្យ៉ាងទៀត តំណាងសហគមន៍មួយចំនួននៅតាមខេត្តមួយចំនួនបានប្រឈមនឹងការធ្វើទុក្ខបុកម្នេញ និងការគំរាមកំហែង ដែលរារាំងពួកគាត់ពីការធ្វើការប្រាស្រ័យទាក់ទងជាមួយដៃគូពាក់ព័ន្ធខាងក្រៅដើម្បីចូលរួមប្រជុំ និងវគ្គបណ្តុះបណ្តាលជាមួយអង្គការ និងរារាំងការរៀបចំព្រឹត្តិការណ៍នានា។

៣. មេរៀន

ថ្វីបើមានការប្រឈមការរឹតត្បិតយ៉ាងណាក្តី ម.ស.ម.ក យល់ឃើញថាការបន្តសកម្មភាពតស៊ូមតិប្រកបដោយគោលការណ៍ ដោយតុល្យភាព និងការចូលរួមក្នុងកិច្ចពិភាក្សាជាមួយដៃគូពាក់ព័ន្ធជាកិច្ចការចាំបាច់ដើម្បីបន្តកិច្ចគាំពារនិងលើកកម្ពស់សិទ្ធិមនុស្ស។ ម.ស.ម.ក នៅតែប្រកាន់គោលជំហរប្រកបដោយគោលការណ៍ទៅលើបញ្ហាសិទ្ធិមនុស្ស ទស្សនៈមិនលម្អៀង និងតុល្យភាព។

៤. យេនឌ័រ និងគោលការណ៍ផ្អែកលើសិទ្ធិជាមូលដ្ឋាន

ក្នុងឆ្នាំ២០១៨ ម.ស.ម.ក បានចាប់ផ្តើមអនុវត្តគម្រោងថ្មីមួយរបស់ខ្លួនឈ្មោះ «សំឡេងយើងដើម្បីសមភាពយេនឌ័រ» ក្នុងគោលបំណងដើម្បីចូលរួមចំណែកលើកកម្ពស់សមភាពយេនឌ័រក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាល និងជីវភាពសាធារណៈនៅកម្ពុជាដោយធានាថាស្ត្រី ក្មេងស្រី និងក្រុមអ្នកស្រឡាញ់ភេទដូចគ្នាទទួលបានសិទ្ធិ និងទទួលបានការគាំទ្រកាន់តែខ្លាំងឡើងពីសំណាក់អាជ្ញាធរ និងសហគមន៍របស់ពួកគាត់។ ក្នុងរយៈពេលនៃរបាយការណ៍នេះ ម.ស.ម.ក បានព្យាយាមជំនះឧបសគ្គនានាដើម្បីឱ្យមានការចូលរួមរបស់ស្ត្រី ដូចជាការធានាភាពជាតំណាងស្មើភាពគ្នារវាងបុរស និងស្ត្រីនៅក្នុងកម្មវិធីនានា។ នៅគ្រប់ពេលទាំងអស់ ម.ស.ម.ក តែងតែលើកឡើងពីហានៈផ្លូវច្បាប់ស្មើភាពគ្នារវាងបុរស ស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នាទាក់ទងនឹងសិទ្ធិមនុស្ស។

លើសពីនោះ ម.ស.ម.ក បានរៀបចំព្រឹត្តិការណ៍សំខាន់មួយចំនួនដើម្បីលើកកម្ពស់ស្ត្រី និងសមភាពយេនឌ័រនៅក្នុងឱកាសនៃទិវានារីអន្តរជាតិ ០៨ មីនា ឆ្នាំ២០១៨ និងនៅតែបន្តផ្តល់ជំនួយផ្នែកច្បាប់ មនុស្សធម៌ និងផ្លូវចិត្តតាមលទ្ធភាពដែលអាចធ្វើទៅបានដល់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នាដែលបានប្រឈមនឹងអំពើហិង្សា ការយាយី និងការគំរាមកំហែងដោយសារការងាររបស់ពួកគេ។

៥. ឧបសម្ព័ន្ធ ៖ ឯកសារចេញផ្សាយសំខាន់ៗរបស់ ម.ស.ម.ក រួមមាន ៖

- របាយការណ៍ប្រចាំឆ្នាំស្តីពី សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា ៖ ការសង្កេតការណ៍សនៅការណ៍នៅសាលាឧទ្ធរណ៍
- ខិត្តប័ណ្ណព័ត៌មាន សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- ខិត្តប័ណ្ណព័ត៌មាន ការត្រួតពិនិត្យជាសកលតាមកាលកំណត់ និងប្រទេសកម្ពុជា បច្ចុប្បន្នភាពត្រឹមថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១៨
- កំណត់ត្រាសង្ខេបស្តីពី ធុរកិច្ច និងសិទ្ធិមនុស្សការទប់ស្កាត់ ការកាត់បន្ថយ និងការដោះស្រាយការរំលោភសិទ្ធិនានាពាក់ព័ន្ធនឹងបញ្ហាដីធ្លីនៅក្នុងព្រះរាជាណាចក្រកម្ពុជា៖ ចំណុចកែលម្អទាំងប្រាំពីរយ៉ាង

--- ចប់ ---